# មេរៀនទី ៣ ៖ កិច្ចការនៃសេចក្ដីសង្គ្រោះ និងភាពតម្កើងឡើង

*អ្នកអាចបង្រៀនមេរៀន នេះម្ដងទាំងមូល ឬបំបែកវា ទៅជា ផ្នែកខ្លីៗ ក៏ បាន ។ សូមសម្របសម្រួលមេរៀនទៅ តាមកាលៈទេសៈនៅ ក្នុងមូលដ្ឋាន និងតម្រូវការ អាយុ ព្រមទាំងការយល់ដឹងនៃគណៈប្រធានកូរ៉ុម ឬថ្នាក់របស់អ្នក ។*

## កិច្ចការនៃគណៈប្រធានកូរ៉ុម ឬថ្នាក់

សូមអញ្ជើញសមាជិកគណៈប្រធានឲ្យអានជាមួយគ្នាក្នុង*សៀវភៅណែនាំទូទៅ ៖ ការបម្រើនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ*១.២ នៅលើគេហទំព័រ ( ChurchofJesusChrist.org ) ហើយអញ្ជើញពួកគេឲ្យរកមើលកិច្ចការដែលព្រះអម្ចាស់បានត្រាស់ហៅឲ្យពួកគេធ្វើ ។ ហេតុអ្វីបានជាកិច្ចការនេះមានសារៈសំខាន់ ? តើមានអ្វីខ្លះដែលយើងកំពុងធ្វើរួចហើយដែលសម្រេចគោលបំណងទាំងនេះ ? តើយើងអាចកំណត់ ឬកែប្រែគោលដៅអ្វីខ្លះដើម្បីសម្រេចគោលបំណងទាំងនេះបានល្អជាងមុន ?

## ការចូលរួមពីសមាជិកកូរ៉ុម ឬថ្នាក់នៅក្នុងកិច្ចការនេះ

សូមឲ្យសមាជិកគណៈប្រធានពិនិត្យមើលឡើងវិញនូវអ្វីដែលពួកគេបានពិភាក្សា និងគ្រោងទុកក្នុងនាមជាគណៈប្រធាន ។ ( អ្នកអាចស្នើសុំឲ្យពួកគេពិនិត្យមើលឡើងវិញពីរបៀបវារៈនៃកិច្ចប្រជុំគណៈប្រធាន រួមបញ្ចូលទាំងផែនការរបស់ពួកគេសម្រាប់ការបម្រើ និងសកម្មភាពផងដែរ ) ។ បន្ទាប់មក សូមសួរសំណួរដូចខាងក្រោមនេះ ៖

- តើយើងបានផ្ដោតអារម្មណ៍យ៉ាងដូចម្ដេចទៅលើកិច្ចការនៃសេចក្ដីសង្គ្រោះ និងភាពតម្កើងឡើង ?
- តើយើងអាចធ្វើការកែលម្អនៅត្រង់កន្លែងណាខ្លះ ?

សូមអញ្ជើញគណៈប្រធានឲ្យពិភាក្សាអំពីរបៀបដែលពួកគេអាចជួយដល់សមាជិកកូរ៉ុម ឬថ្នាក់របស់ពួកគេឲ្យចូលរួមកាន់តែពេញទំហឹងនៅក្នុងកិច្ចការនៃសេចក្ដីសង្គ្រោះ និងភាពតម្កើងឡើង ។ សំណួរដូចខាងក្រោមអាចត្រូវបានពិភាក្សាដោយគណៈប្រធាន ឬដោយកូរ៉ុម ឬថ្នាក់ ៖

- តើយើងអាចជួយគ្នាទៅវិញទៅមកឲ្យរស់នៅតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទយ៉ាងដូចម្ដេច ?
- តើយើងអាចធ្វើអ្វីខ្លះដើម្បីមើលថែដល់អ្នកទីទ័ល ?
- តើយើងអាចជួយមនុស្សទាំងអស់គ្នាឲ្យមានអារម្មណ៍ថាត្រូវបានអញ្ជើញ និងស្វាគមន៍ឲ្យមកចូលរួមជាមួយយើងដោយរបៀបណា ?
- តើយើងអាចលើកទឹកចិត្តដល់ការចូលរួមនៅក្នុងកិច្ចការពង្សប្រវត្តិ និងព្រះវិហារបរិសុទ្ធយ៉ាងដូចម្ដេច ?

( សូមមើលសំណួរផ្សេងទៀតដែលអាចមាននៅក្នុងវគ្គ « ប្រឹក្សារួមគ្នា » នៅក្នុងមេរៀននីមួយៗនៃ *ចូរមកតាមខ្ញុំ— សម្រាប់កូរ៉ុមបព្វជិតភាពអើរ៉ុន និងថ្នាក់យុវនារី* ។

## ធនធានគាំទ្រ

- *សៀវភៅណែនាំទូទៅ* ជំពូកទី ១
- វីដេអូ « Youth Responsibility in the Work of Salvation »
- ខារ៉ុល អេហ្វ ម៉ាកខនគី « នៅទីនេះដើម្បីបម្រើបុព្វហេតុសុចរិត » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៥ ទំព័រ ១២–១៤
- អេភេសូរ ៤:១១–១៣; ម៉ូរ៉ូណៃ ១០:៣២; ម៉ូសេ ១:៣៩

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2020 by Intellectual Reserve, Inc. All rights reserved. 4/20 ។ ការបកប្រែនៃ *Quorum and Class Presidency Training—Lesson 3*. Cambodian. PD60011121 258. បោះពុម្ពនៅសហរដ្ឋអាមេរិក